**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០៨៦៧ ព.ណ...អ.ក.ល

ថ្ងៃចន្ទ ៨ កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ មេសា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ.អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ដល់៣០ ខែមេសា ឆ្នាំ២០២១ នឹងត្រូវលក់៣.៨៦០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៤១០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត ចាប់ពីថ្ងៃទី១៦ ដល់៣០ ខែមេសា ឆ្នាំ២០២១ នឹងចុះមក៣.៧០០រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.២៥០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | **Average MOPS** | ០,៤៤២៣ដុល្លារ | ០,៤២៣៣ ដុល្លារ |
| ២ | ពន្ធ៖ | ០,១៨៤៧ ដុល្លារ | ០,០៧៤២ ដុល្លារ |
| | ពន្ធគយ | ០,០៦៣៥ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,១០១៣ ដុល្លារ | ០,០៣៤២ ដុល្លារ |
| ៣ | **PREMIUM** | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៨២៧ ដុល្លារ | ០,០៧២៨ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩០៩៧ ដុល្លារ | ០,៨០០៣ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.៦៨២ រៀល | ៣.២៥០ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩១ ដុល្លារ | ០,៨០ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.៧០០ រៀល | ៣.២៥០ រៀល |

សម្គាល់៖ អាត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ ដែលស្មើនឹង៤០៤៨រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង DO 0.05% (USD/Barrel) |
|---|---|---|
| ១ មេសា ២០២១ | ៧០,២១ | ៦៥,៤៨ |
| ៥ មេសា ២០២១ | ៧០,៨៧ | ៦៧,១២ |
| ៦ មេសា ២០២១ | ៧០,៥៣ | ៦៧,២៤ |
| ៧ មេសា ២០២១ | ៧២,៥៣ | ៧២,១៦ |
| ៨ មេសា ២០២១ | ៦៩,៥០ | ៦៦,៩០ |
| ៩ មេសា ២០២១ | ៦៩,១៧ | ៦៦,៧៣ |
| ១២ មេសា ២០២១ | ៦៩,៥៤ | ៦៧,១៧ |
| ១៣ មេសា ២០២១ | ៦៩,៩៤ | ៦៧,៣៥ |
| ១៤ មេសា ២០២១ | ៧១,០៩ | ៦៨,៥១ |
| ១៥ មេសា ២០២១ | ៧២,៨៧ | ៧០,០៤ |
| មធ្យមភាគ១០ថ្ងៃ | ៧០,៣២៣០ | ៦៧,៣០៩០ |
| មធ្យមភាគ (ដុល្លារ/លីត្រ) | ០,៤៤២៣ | ០,៤២៣៣ |

## ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១ ខែកុម្ភៈ ដល់ ១៦ ខែមេសា ឆ្នាំ២០២១




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់។

ក្រសួងពាណិជ្ជកម្ម